**ព្រះរាជាណាចក្រកម្ពុជា**

**សាលាឧទ្ធរណ៍** **ជាតិ សាសនា ព្រះមហាក្សត្រ**

សំណុំរឿងព្រហ្មទណ្ឌ **លិខិតជូនដំណឹងពីសាលដីកាកំបាំងមុខ**

លេខ ១៦៧/១១-០៣-១០ **យើង ប៉ោ សុន្ថារ៉ា ក្រឡាបញ្ជីសាលាឧទ្ធរណ៍**

**សាលដីកា**

លេខ ៥៩"ង" ចុះថ្ងៃទី ១៣-១០-២០១០

ប្រាប់មកឈ្មោះ **សម រង្ស៊ី** ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ មុខរបរ អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម និងជាប្រធានគណៈបក្សសមរង្ស៊ី (គេចខ្លួន)។ ឲ្យដឹងថា សាលដីកាព្រហ្មទណ្ឌលេខ ៥៩"ង" ចុះថ្ងៃទី ១៣-១០-២០១០ សាលាឧទ្ធរណ៍បានសម្រេចសេចក្ដីដូចខាងក្រោម ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០២-២០១០ របស់លោក ជូង ជូងី ជាមេធាវីតំណាងទទួលសិទ្ធិឲ្យឈ្មោះ សម រង្ស៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយគតិច្បាប់។

២-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០២-២០១០ របស់ឈ្មោះ មាស ស្រី និងឈ្មោះ ព្រុំ ជា ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ០១ (ក) ចុះថ្ងៃទី ២៧-០១-២០១០ របស់សាលាដំបូងខេត្តស្វាយរៀង ទុកជាបានការ លើកលែងតែចំណុចទី១"ខ" ស្ដីពីទណ្ឌកម្មពន្ធនាគារលើឈ្មោះ ព្រុំ ជា និងឈ្មោះ មាស ស្រី កំណត់ចំនួន ០១ឆ្នាំ ត្រូវកែប្រែមកទោសពន្ធនាគារចំនួន ០៩ខែ ២០ថ្ងៃ វិញ រីឯទោសនៅសល់ត្រូវព្យួរ តាមមាត្រា ៩៤ និងតាមមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

៤-ចំណុចផ្សេងពីនេះ នៃសាលក្រមរក្សាទុកជាបានការដដែល។

៥-ដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ សម រង្ស៊ី លេខ ០៨ ដចខ ចុះថ្ងៃទី ២៨-០១-២០១០ របស់ចៅក្រមជំនុំជម្រះសាលាដំបូងខេត្តស្វាយរៀង ត្រូវបន្តអានុភាព។

៦-សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី ០៥-១០-២០១០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៣-១០-២០១០ ចំពោះមុខមេធាវីការពារសិទ្ធិឲ្យពិរុទ្ធជន ចំពោះមុខពិរុទ្ធជនឈ្មោះ មាស ស្រី និងឈ្មោះ ព្រុំ ជា កំបាំងមុខពិរុទ្ធជនឈ្មោះ សម រង្ស៊ី ចំពោះមុខមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណី។

បើកផ្លូវប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា **ប៉ោ សុន្ថារ៉ា** | ហត្ថលេខា **សំរឹទ្ធិ សុផល .ចាន់ ម៉ាឌីណា** | ហត្ថលេខា **ឃុន លាងម៉េង** |

---

សាមីខ្លួនមានសិទ្ធប្ដឹងទាស់ក្នុងរយៈពេល ១៥ថ្ងៃ និងសាទុក្ខរយៈពេល ១ខែ ក្រោយពីបានទទួលលិខិតជូនដំណឹងនេះ។

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

បានឃើញ　　　　សាលាឧទ្ធរណ៍ថ្ងៃទី ១០ ខែ 10 ឆ្នាំ ២០១០

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**　　　　**ក្រឡាបញ្ជី**

**ឃុន_លាងម៉េង**　　　　**ប៉ោ_សុន្ថារ៉ា**